# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

**សំណុំរឿងលេខ:** ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ:** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ដាក់ជូន:** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2016, 09:25
CMS/CFO: Ly Bunloung

## ចំណាត់ថ្នាក់ឯកសារ

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សម្ងាត់

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ**

**អាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

# សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យមានកិច្ចស៊ើបសួរប្រឆាំង អោ អាន [redacted] ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ

---

**ដាក់ដោយ៖**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គីមសួន

ស៊ិន សុវ៉ន

ឡោ ជុនធី

Beini YE

Linda BEHNKE

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicolas KOUMJIAN

**ជនត្រូវចោទ៖**

[redacted]

អោ អាន

**សហមេធាវីការពារក្តី៖**

មុំ លុជ្ស

Richard ROGERS

Göran SLUITER

ស៊ូ មូស្ស៊ែន្នី

Suzana TOMANOVIĆ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**ក្នុងសំណុំរឿង ០០៤ ទាំងអស់**

## I. សេចក្តីផ្តើម

1. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("ម.ត.ដ.រ") ដែលមានឈ្មោះដូចខាងក្រោម សូមដាក់ជូនសំណើនេះដោយគោរព សុំឱ្យមានកិច្ចស៊ើបសួរបន្ថែម អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង (វ.ផ) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

2. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬ យេនឌ័រ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤") សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) បានបង្ហាញភ័ស្តុតាងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រក្នុងស្រុកនានាស្ថិតក្រោមការគ្រប់គ្រង ឬអំណាចរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៤[1]។ យើងយល់ឃើញថា ការចោទប្រកាន់ផ្នែកអង្គហេតុដែលមានបង្ហាញនៅទីនេះ អាចក្លាយទៅជាឧក្រិដ្ឋកម្មដោយឡែកនៃការមានផ្ទៃពោះដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មមួយប្រឆាំងមនុស្សជាតិក្នុងទម្រង់ជា "អំពើអមនុស្សធម៌ផ្សេងៗ"។ ដើម្បីបង្ហាញធាតុផ្សំទាំងអស់នៃឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ កិច្ចស៊ើបសួរបន្ថែមគឺជាចាំបាច់។

3. ហេតុដូច្នេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះដូចខាងក្រោម សូមគោរពស្នើដោយគោរពដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) អនុវត្តការស៊ើបអង្កេតបន្ថែម ដើម្បីកំណត់ពីចេតនារបស់ជនសង្ស័យ អោ អាន [redacted] ក្នុងសំណុំរឿង ០០៤ ដែលបានប្រព្រឹត្តការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ តាមរយៈការឃុំខ្លួនមនុស្សស្រីម្នាក់ ឬច្រើននាក់រហូតដល់មានផ្ទៃពោះដោយបង្ខំ។

[1] ការិយាល័យសហព្រះរាជអាជ្ញា, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D19**, *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬ យេនឌ័រ*, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ [អំណើះតទៅហៅថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤"], កថាខណ្ឌ ១។

## II. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដោយបើកឲ្យមានកិច្ចស៊ើបសួរមួយដោយបានកំណត់ឈ្មោះ អោ អាន (*ហៅ* តា អាន) [redacted] និង អ៊ឹម ចែម ថាជាជនសង្ស័យសម្រាប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤[2]។ ក្រោយមក សហចៅក្រមស៊ើបអង្កេត បានបើកការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មនានា ដែលបានចោទប្រកាន់ ដែលមានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ។ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយ ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ[3]។

5. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ”) បានដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[4]។ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ ក្នុងគ្រាដែលមានវត្តមានរបស់គាត់ ស.ច.ស.អ បានជូនដំណឹងដល់ អោ អាន អំពីបទល្មើសនានាដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងរូបគាត់ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពាន មាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[5]។ នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស.អ បានចោទប្រកាន់ [redacted] ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[6]។

---

[2] ការិយាល័យសហព្រះរាជអាជ្ញា, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D1**, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា*, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ [អំណើះតទៅហៅថា “ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី”]។

[3] ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤, ឯកសារ **D191**។

[4] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D239**, *ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ*, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥។

[5] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D242**, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង*, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[6] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D281**, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង*, ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥។

6. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានជូនដំណឹងដល់ភាគីទាំងអស់ និងមេធាវីរបស់ពួកគេអំពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម ហើយបានចេញសេចក្ដីជូនដំណឹងដែលថា ពួកគេមានបំណងច្រានចោលការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម[7]។ នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស.ច.ស បានចេញដីកាសម្រេចបំបែកសំណុំរឿងទាក់ទងនឹង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤[8]។

## III. សំណើសុំបន្ថែមចំនួនទំព័រ និងដាក់ឯកសារតែមួយភាសា

7. មាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ ជាទូទៅដាក់កម្រិតកំណត់ឯកសារដែលត្រូវដាក់បញ្ជូនទៅកាន់ ក.ស.ច.ស ត្រឹមចំនួន ១៥ ទំព័រប៉ុណ្ណោះជាភាសាអង់គ្លេស។ ទោះជាយ៉ាងណា មាត្រា ៥.៤ អនុញ្ញាតឲ្យ ក.ស.ច.ស ផ្ដល់ការបន្ថែមចំនួនទំព័រក្នុងកាលៈទេសៈលើកលែងចំនួន។

8. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានឈ្មោះដូចខាងក្រោម លើកឡើងថា ការដាក់ឯកសារបច្ចុប្បន្ន បង្កឲ្យមានបញ្ហាស្មុគស្មាញ ដោយសារវាតម្រូវឲ្យមានការវិភាគស៊ីជម្រៅលើឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ ដែលមិនត្រូវបានដោះស្រាយក្នុងកិច្ចដំណើរការនីតិវិធីណាមួយនៅ អ.វ.ត.ក ពីមុនមក។ ការណ៍នេះមិនត្រឹមតែពាក់ព័ន្ធនឹងការពិចារណាលើប្រភពផ្លូវច្បាប់ជាតិ និងអន្តរជាតិមួយចំនួន និងការពិភាក្សាអំពីទស្សនកិច្ចរណ៍មួយចំនួនធំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងបទបង្ហាញ និងការវិភាគអំពីអង្គហេតុដែលពាក់ព័ន្ធផងដែរ។ ហេតុដូច្នេះ យើងស្នើដោយគោរពដល់ ក.ស.ច.ស សុំបន្ថែមទំព័ររហូតដល់ ២៥ទំព័រ។

9. សំណើនេះត្រូវបានដាក់ជូនជាភាសាអង់គ្លេស ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវបានដាក់ជូនក្នុងពេលឆាប់បំផុត។ មាត្រា ៧.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ នៅចំពោះមុខ

---

[7] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D285**, *សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម*, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។ ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D286**, *សេចក្ដីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់*, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។

[8] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D286/7**, *ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤*, ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៥។

អ.វ.ត.ក[9] ចែងអំពីវិធានទូទៅ ដែលឯកសារត្រូវបានដាក់ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬបារាំង ប៉ុន្តែមាត្រា ៧.២ ចែងថា ក្នុងកាលៈទេសៈលើកលែង ក.ស.ច.ស អាចអនុញ្ញាតឱ្យដាក់ឯកសារជាភាសាអង់គ្លេសជាមុនសិន ដោយអត្ថបទបកប្រែជាភាសាខ្មែរនឹងត្រូវបានដាក់ជូនក្នុងពេលឆាប់បំផុត។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការដាក់ឯកសារនេះ គួរត្រូវបានចាត់ទុកថាជាករណីលើកលែង។ សំណើសុំឱ្យមានកិច្ចស៊ើបសួរអំពីការមានផ្ទៃពោះដោយបង្ខំអាចនឹងនាំឱ្យមានការសម្ភាសសាក្សីជាច្រើននាក់បន្ថែមទៀត ហើយកិច្ចស៊ើបសួរផ្សេងទៀតនឹងត្រូវបានធ្វើឡើង។ ដោយសារការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ កំពុងដើរឆ្ពោះទៅរកការបញ្ចប់ប្រកបដោយយ៉ាងលឿននោះ ប្រការសំខាន់សម្រាប់ការដាក់ឯកសារនេះគឺត្រូវទទួលបានការពិចារណាពីសំណាក់ ក.ស.ច.ស យ៉ាងហោចណាស់ជាភាសអង់គ្លេសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## IV. ច្បាប់ជាធរមាន

10. ដូចដែលការបង្ហាញអំពីគោលការណ៍ជាមូលដ្ឋានរបស់ អ.វ.ត.ក និងកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ **វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង** ចែងអំពីសិទ្ធិរបស់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការស្នើសុំឱ្យមានកិច្ចស៊ើបសួរ៖

> *នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋ-ប្បវេណី អាចស្នើសុំសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ [...]។*

11. លើសពីនេះទៀត **វិធាន ២៣(១)** នៃវិធានផ្ទៃក្នុង ចែងក្នុងផ្នែកដែលពាក់ព័ន្ធ ថា៖

> *គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី៖*

[9] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី ៨, ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ [អំណើះតទៅហៅថា "សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ"]។

*ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់។*

12. ទាក់ទងនឹងអង្គសេចក្ដីនៃការដាក់សារណានេះ **មាត្រា ៥** នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[10] ចែងថា៖

*អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖*

- *ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទេសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត។*

## V. ភាពអាចទទួលយកបាន

13. ការដាក់សារណាបច្ចុប្បន្ន ត្រូវបានធ្វើឡើងទាន់ពេលវេលា។ អនុលោមតាម**វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង** ដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិស្នើសុំឱ្យមានកិច្ចស៊ើបសួរនៅពេលណាមួយក្នុងអំឡុងពេលនៃការស៊ើបអង្កេត នៅពេលដែលខ្លួនគិតថាមានប្រយោជន៍។

## VI. អង្គហេតុពាក់ព័ន្ធនឹងសំណើ

[10] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ [អំណើះតទៅហៅថា "ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក], មាត្រា ៥។

14. គោលដៅចម្បងនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") គឺត្រូវកែសម្រួលរាល់ទិដ្ឋភាពទាំងអស់របស់សង្គម និងវប្បធម៌ខ្មែរ ដើម្បីធ្វើឱ្យស៊ីគ្នាទៅនឹងមនោគមវិជ្ជាកុម្មុយនីស្តជ្រុលនិយមរបស់ពួកគេ[11]។ ការណ៍នេះបានបង្កឱ្យមានការជម្លៀសប្រជាជនចេញពីទីក្រុង និងធ្វើឱ្យប្រជាជនទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្លាយទៅជាទាសករដែលស្ថិតក្នុងការគ្រប់គ្រងដ៏ឃោរឃៅ និងក្នុងសហករណ៍កសិកម្ម រោងចក្រ និងការដ្ឋានការងារប្រកបដោយអមនុស្សធម៌[12]។

15. ជាផ្នែកមួយនៃការផ្លាស់ប្តូរមនោគមវិជ្ជានេះ រចនាសម្ព័ន្ធគ្រួសារបែបប្រពៃណី ត្រូវបានបំផ្លិចបំផ្លាញ ហើយ ប.ក.ក បានប៉ុនប៉ង់កសាងសង្គមឡើងវិញក្នុងរូបភាពជាគ្រួសារសហករណ៍ក្រោមការដឹកនាំរបស់*អង្គការ*[13]។ ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចក្នុងសំណុំរឿង ០០២/១ ថា បទប្បញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍ គឺជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយសំខាន់ៗរបស់ ប.ក.ក[14]។ គ្រួសារដែលមានស្រាប់ ជាធម្មតាត្រូវបានបំបែកចេញពីគ្នាដោយសារសមូហភាវូនីយកម្មការងារ និងការរៀបចំឱ្យរស់នៅ ដើម្បីធានាឱ្យបាននូវភាពស្មោះស្ម័គ្រដាច់ខាតចំពោះបុព្វហេតុបដិវត្តន៍[15]។

---

[11] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ឯកសារ **D427**, *ដីកាដំណោះស្រាយ*, កថាខណ្ឌ ១៥៦។ Maria Lobato, "ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម", (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ៩, ភ្ជាប់ជាឧបសម្ព័ន្ធ ១។

[12] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ឯកសារ **D1**, កថាខណ្ឌ ៧។ អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១១២, ១១៦, ១៣២, ភ្ជាប់ជាឧបសម្ព័ន្ធ ២។

[13] Elizabeth Becker, "*នៅពេលដែលសង្គ្រាមរលត់ទៅ*" (ឆ្នាំ ១៩៨៦), ទំព័រ ២២៦, ភ្ជាប់ជាឧបសម្ព័ន្ធ ៣។ ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ឯកសារ **E427**, *ដីកាដំណោះស្រាយ*, កថាខណ្ឌ ១៨។ អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១៩៩, ២២១។

[14] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១៣០។

[15] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១១៦, ៤៦៦, ៦០១, ៦០៩។

16. បុរស និងស្ត្រីមិនទាន់រៀបការ ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាប្រព័ន្ធ ដែលត្រូវបានរៀបចំដោយ ប.ក.ក ហើយក្រោយមកបង្ខំឱ្យពួកគេរួមដំណេក[16]។ ជនរងគ្រោះត្រូវបានបង្ខំឱ្យទទួលយកអាពាហ៍ពិពាហ៍បែបនេះ ក្នុងបរិបទរបបជិះជាន់មួយដែលព្យាយាមអនុវត្តការគ្រប់គ្រងទាំងស្រុងទៅលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់បុគ្គលិកម្នាក់ៗ[17]។ ក្នុងករណីជាច្រើន ការរួមភេទដើម្បីបំពេញកាតព្វកិច្ចអាពាហ៍ពិពាហ៍បានកើតមានឡើងក្រោមការបញ្ជាយ៉ាងជាក់លាក់ និងការគំរាមកំហែងដាក់ទណ្ឌកម្ម ដូចមានបង្ហាញក្នុងភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤[18]។ វាជាឧបករណ៍មួយ ដែល ប.ក.ក បានប្រើប្រាស់ក្នុងចំណោមឧបករណ៍ផ្សេងៗ ទៀត ដូចជា ការឃុំខ្លួនតាមតែអំពើចិត្ត ការសម្លាប់ក្រៅច្បាប់ និងការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ដើម្បីធានាឱ្យបាននូវការគោរពរបបនេះឱ្យបានពេញលេញ និងដើម្បីបង្កឱ្យមានបរិយាកាសភ័យខ្លាច និងមិនទុកចិត្តគ្នាក្នុងចំណោមប្រជាជន[19]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានរួមចំណែកដល់គោលដៅទាំងនេះ តាមរយៈការពង្រឹងវិធានការស្តាប់បង្គាប់ និងការទប់ស្កាត់មិនឱ្យមានទំនាក់ទំនងជិតស្និទ្ធនានាដោយផ្អែកលើការស្រឡាញ់គ្នា[20]។

[16] សម្រាប់ព័ត៌មាន និងភ័ស្តុតាងបន្ថែម សូមមើល៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឆ្នាំ ២០១៤, ឯកសារ **D191**, កថាខណ្ឌ ២, ៣, ៤។

[17] *សូមមើល* ការពិពណ៌នាក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ឯកសារ **D1**, កថាខណ្ឌ ៦-៨។

[18] ចិច សុផា, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស , ឯកសារ **D219/42**, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ទំព័រ ២០។ កែវ ធារី, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/113**, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៤, ទំព័រ ១៦។ លី លន់, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D118/248**, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៤, ទំព័រ ២២។ សិន បាន, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/306**, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤, ទំព័រ ៧។

[19] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D427**, *ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥៧* ។

[20] កែវ ស៊ិន, *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/101**, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ទំព័រ ៩។

17. ជាងនេះទៀត ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាឧបករណ៍មួយសម្រាប់បញ្ជា និងគ្រប់គ្រងពេលវេលា និងទីកន្លែងបន្តពូជ[21]។ ក្នុងពេលអនុវត្តមនោគមវិជ្ជាបដិវត្តន៍កសិកម្មរបស់ខ្លួន ប.ក.ក បានប្រឈមនឹងការបាត់បង់ចំនួនប្រជាជនយ៉ាងច្រើនដែលបណ្ដាលមកពីការកាប់សម្លាប់ ការបង្អត់អាហារ ជំងឺ ឬការបាក់កម្លាំងដោយសារលក្ខខណ្ឌការងារធ្ងន់ធ្ងរ ដែលពួកគេចាំបាច់ត្រូវប៉ះប៉ូវចំពោះការបាត់បង់ទាំងអស់នេះមកវិញ[22]។ ជាលទ្ធផល ប.ក.ក ត្រូវតែបង្កើនអត្រាកំណើតក្នុងចំណោមប្រជាជនកម្ពុជា[23]។ ដូច្នេះ គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍មិនមែនជាការបង្កើតទំនាក់ទំនងរវាងប្ដីប្រពន្ធដោយខ្លួនឯងនោះទេ ប៉ុន្តែវាជាមធ្យោបាយមួយដើម្បីធានាឲ្យបាន កំណើនប្រជាជន និងពង្រឹងកម្លាំងពលកម្មរបស់របបនេះ[24]។

18. ការសន្និដ្ឋាននេះទទួលបានគាំទ្រពីអង្គហេតុដែលថា គូស្វាមីទើបនឹងរៀបការត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយគ្នាតែប៉ុន្មានថ្ងៃប៉ុណ្ណោះ មុនពេលពួកគេត្រូវបានបំបែកម្ដងទៀតឲ្យទៅធ្វើការនៅអង្គភាពការងាររៀងៗខ្លួន[25]។ ការរៀបរាប់ពីព្រឹត្តិការណ៍របស់សាក្សីមួយចំនួន បញ្ជាក់ពីគោលនយោបាយមួយរបស់ ប.ក.ក ក្នុងការបង្កើនអត្រាកំណើត រួមទាំងសាក្សីម្នាក់ក្នុងសំណុំរឿង ០០២[26] ជាអ្នកដែលបានផ្ដល់សក្ខីកម្មថា គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយជាមួយ ប៉ុល ពត នៅខែមិថុនា ឆ្នាំ ១៩៧៨ ដែលក្នុងកិច្ចប្រជុំនោះ គាត់បានពិភាក្សាអំពីតម្រូវការបង្កើនចំនួនប្រជាជនឲ្យកើនដល់ចន្លោះពី ២០ ទៅ ៣០ លាននាក់ ដើម្បីឲ្យមានកម្លាំងគ្រប់គ្រាន់ក្នុងការការពារប្រទេសជាតិ។ ដើម្បីសម្រេចគោលដៅនេះ ប៉ុល ពត បានណែនាំកម្មាភិបាលថ្នាក់ក្រោមឲ្យរៀបចំអាពាហ៍

---

[21] Kalyanee Mam, *"កម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៦-១៩៧៩)៖ ស្ត្រីជាឧបករណ៍សម្រាប់ការផ្លាស់ប្ដូរសង្គម"*, (ឆ្នាំ ២០០០), មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រ ៣៥-៣៧, ភ្ជាប់ជាឧបសម្ព័ន្ធ ៤។

[22] Meng-Try Ea,"និន្នាការប្រជាជនបច្ចុប្បន្នក្នុងប្រទេសកម្ពុជា" ក្នុងសៀវភៅរបស់ David A. Ablin និង Marlowe Hood ក្រោមចំណងជើងថា ភាពឈឺចាប់របស់កម្ពុជា, ទំព័រ ៦-៧, ភ្ជាប់ជាឧបសម្ព័ន្ធ ៥។

[23] María Lobato, "ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម" (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ១២។

[24] Beini Ye,*"អាពាហ៍ពិពាហ៍ដោយបង្ខំជាកញ្ចក់នៃការផ្លាស់ប្ដូរជម្លោះ"* ក្នុងទស្សនាវដ្ដី *Peace Review: A Journal of Social Justice*, ២៣:៤ (ឆ្នាំ ២០១១), ទំព័រ ៤៧០, ភ្ជាប់ជាឧបសម្ព័ន្ធ ៦។

[25] Kalyanee Mam, "កម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៦-១៩៧៩)៖ ស្ត្រីជាឧបករណ៍សម្រាប់ការផ្លាស់ប្ដូរសង្គម", (ឆ្នាំ ២០០០), មជ្ឈមណ្ឌលឯកសារកម្ពុជា, ទំព័រ ៣៥។

[26] ជួន ធី ហៅ ធី ឌី, *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី*, សំណុំរឿង ០០២/១៤-០៨-២០០៦, ឯកសារ **D117/36.1.3**, *ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១០, ទំព័រ ៤។*

ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជន។ បទសម្ភាសន៍ជាមួយសាក្សីផ្សេងទៀតជាច្រើនអះអាងអំពីការអនុវត្តផែនការនេះ[27]។ សាក្សីម្នាក់បានថ្លែងថា៖

> *"ប្រធានភូមិប្រាប់ខ្ញុំឲ្យរួមភេទជាមួយប្តីរបស់ខ្ញុំ។ [...] បើសិនជាខ្ញុំបន្តរឹងទទឹង ប្រធានភូមិនឹងរាយការណ៍ទៅថ្នាក់លើ ហើយគេនឹងមកនាំខ្ញុំទៅសម្លាប់ចោល ទៅយប់នោះហើយ[28]"*។

## VII. ឧទ្ធិករណ៍

### ក. គោលការណ៍នៃនីត្យានុកូលភាព

19. ការស៊ើបអង្កេត និងការចោទប្រកាន់ពីឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ ដែលជាផ្នែកមួយនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនរំលោភគោលការណ៍នៃនីត្យានុកូលភាពនោះឡើយ។

20. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្ត ត្រង់ចំណុច "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។ ចំណុចនេះត្រូវបានបង្ហាញ នៅ យុត្តិសាស្ត្រមុនៗ របស់ អ.វ.ត.ក។ ក្នុងសំណុំរឿង ០០២/០១ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានសម្រេចថា ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ក្នុងមាត្រា ៥ នៃច្បាប់ស្តីពី អ.វ.ត.ក គឺ

---

[27] ស្រី សឿម, *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/125**, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤, ទំព័រ ១៣។ ព្រាប សុខឿន, *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/24**, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៤, ទំព័រ ១១។ ណាគ្រីមាស, *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D118/212**, ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ ១៩។

[28] ថន យ៉ង់, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/136**, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤, ទំព័រ ១២។

ជាឧក្រិដ្ឋកម្មមួយដែលពាក់ព័ន្ធនឹងលក្ខណៈដែលជាប់មកជាមួយ[29] ហើយជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានតម្កល់សេចក្ដីសម្រេចនេះ[30]។

21. ការទទួលស្គាល់ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ថាជាឧក្រិដ្ឋកម្មដោយឡែកមួយប្រឆាំងនឹងមនុស្សជាតិស្ថិតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានភាពស្របគ្នាទៅនឹងយុត្តិសាស្ត្រអន្តរជាតិដ៏យូរអង្វែង និងដែលត្រូវបានបង្ហាញយ៉ាងច្បាស់លាស់។ ដោយចាប់ផ្ដើមពីធម្មនុញ្ញទីក្រុង Nuremberg នៅតុលាការយោធាអន្តរជាតិ[31] ឧក្រិដ្ឋកម្មនេះត្រូវបានទទួលស្គាល់ ហើយក្រោយមកត្រូវបានប្រើប្រាស់ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR") តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ("SCSL") ហើយជាចុងក្រោយត្រូវបានប្រើប្រាស់ដោយ អ.វ.ត.ក[32]។ ការទទួលស្គាល់កាន់តែ

---

[29] អង្គបុរេជំនុំជម្រះ, សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥), ឯកសារ **D427/1/30**, *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ*, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ៣៧៨, ភ្ជាប់ជាឧសម្ព័ន្ធ ៧។

[30] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៥-៤៣៧។

[31] កិច្ចព្រមព្រៀងស្ដីពីការចោទប្រកាន់ និងការដាក់ទោសឧក្រិដ្ឋជនសង្គ្រាមធំៗនៃក្រុមសម្ព័ន្ធភាពរបស់ណាស៊ីអឺរ៉ុប និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ("ធម្មនុញ្ញក្រុង Nuremberg"), ៨២ U.N.T.S.២៧៩, ដែលបានចូលជាធរមាននៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥។ មាត្រា ៦(គ) ចែងថា៖ "*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ រួមមាន មនុស្សឃាត ការសម្លាប់បំផុតពូជ ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តិប្រឆាំងនឹងប្រជាជនស៊ីវិលណាម្នាក់មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា ក្នុងការប្រព្រឹត្តិ ឬមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មណាមួយស្ថិតក្នុងយុត្តិធិការរបស់តុលាការ ថាតើការប្រព្រឹត្តឧក្រិដ្ឋកម្មនោះបានរំលោភបំពានលើច្បាប់ក្នុងស្រុករបស់ប្រទេសនោះឬយ៉ាងណា*", ភ្ជាប់ជាឧបសម្ព័ន្ធ ៨។

[32] **ICTY៖** *ព្រះរាជអាជ្ញា v.Stakic,* IT-97-24-A, សាលក្រម (អង្គជំនុំជម្រះតុលាការកំពូល), ថ្ងៃទី ២២ ខែ មីនា, កថាខណ្ឌ ៣១៥ ["អំណឺះតទៅហៅថា សាលក្រមអង្គជំនុំជម្រះតុលាការកំពូលសំណុំរឿង *Stakic*"], ភ្ជាប់ជាឧបសម្ព័ន្ធ ៩។ **ICTR៖** ព្រះរាជអាជ្ញា v.Nyiramusuhuko *និងផ្សេងៗទៀត*., ICTR-98-42-T, សាលក្រម និងការកាត់ទោស (អង្គជំនុំជម្រះសាលាដំបូង II), ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១, កថាខណ្ឌ ៦១២៧, ភ្ជាប់ជាឧបសម្ព័ន្ធ ១០។ **SCSL៖** *ព្រះរាជអាជ្ញា v. Brima និងផ្សេងៗទៀត*,, SCSL-04-16-A, សាលក្រម (អង្គជំនុំជម្រះតុលាការកំពូល), ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៨ ("សាលក្រមអង្គជំនុំជម្រះតុលាការកំពូល AFRC"), កថាខណ្ឌ ១៨៣, ១៩៨, ភ្ជាប់ជាឧបសម្ព័ន្ធ ១១។ **អ.វ.ត.ក**៖ អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៥-៤៣៧។

ច្រើនលើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ថាជាប្រភេទដែលនៅសេសសល់មួយនោះ មានគោលបំណងយ៉ាងច្បាស់លាស់ ដើម្បីកំណត់ពីលក្ខណៈទាំងអស់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមិនត្រូវបានរៀបរាប់ជាក់ច្បាស់។

22. រហូតមកត្រឹមឆ្នាំ ១៩៧៥ មិនមានមន្ទិលសង្ស័យនោះទេថា ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មនីមួយៗត្រូវបានបង្ហាញ ទាក់ទងនឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ស្ថិតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅពេលនោះ ធាតុផ្សំនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មានភាពជាក់លាក់គ្រប់គ្រាន់ ហើយហេតុដូចនេះ ជនត្រូវចោទអាចប្រមើលមើលដឹងថា ការអនុវត្តគោលនយោបាយទូទាំងប្រទេសមួយដែលធ្វើឲ្យប្រជាជនស៊ីវិលមានគ្រោះថ្នាក់ និងឈឺចាប់យ៉ាងខ្លាំងនោះ អាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងសំណុំរឿង ០០២ អ.ប.ជ បានលើកឡើងអំពីបញ្ហាផ្លូវច្បាប់ដូចគ្នានេះ[33]។

> *"ដើម្បីឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យជាសត្យានុម័ត ចំពោះលក្ខខណ្ឌនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និលក្ខខណ្ឌនៃភាពអាចដឹងថាមានច្បាប់ចែងបាននោះ គេត្រូវរកឲ្យឃើញយ៉ាងពេញលេញថា សញ្ញាណនៃអំពើឧក្រិដ្ឋមានភាពច្បាស់លាស់នៅក្នុងន័យថា "មានការយល់ដឹងជាទូទៅ" ដោយមិនចាំបាច់យោងទៅដល់ច្បាប់ដែលមានចែងជាលាយលក្ខណ៍អក្សរទេ។ សញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានចែងនៅក្នុងច្បាប់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមុនឆ្នាំ ១៩៧៥"។*

23. សាលក្រមនេះឆ្លើយតបទៅនឹងអង្គហេតុនៃអង្គជំនុំជម្រះតុលាការកំពូល ICTY[34]។ ក្នុងសំណុំរឿង *Stakic* អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចដោយយោងតាមធម្មនុញ្ញទីក្រុង Nuremberg ធម្មនុញ្ញក្រុងតូក្យូ និងប្រភពនានាដែលពាក់ព័ន្ធ[35]៖

> *"សញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" [...] មិនអាចត្រូវបានចាត់ទុកថាជាការរំលោភបំពានលើគោលការណ៍នៃការប្រព្រឹត្តិដែលមិនត្រូវបានកាត់ទោសជាទម្រង់អំពើ*

[33] អង្គបុរេជំនុំជម្រះ, សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥), ឯកសារ **D427/1/30**, *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ*, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ៣៨៥។

[34] សាលក្រមអង្គជំនុំជម្រះតុលាការកំពូលសំណុំរឿង *Stakic*, កថាខណ្ឌ ៣១៥។

[35] សាលក្រមអង្គជំនុំជម្រះតុលាការកំពូលសំណុំរឿង *Stakic*, ជើងទំព័រ ៦៤៩។

*ឧក្រិដ្ឋកម្មទេ លុះត្រាណាមានច្បាប់ចែង (nullem crimen sine lege) នោះទេ ដោយសារវាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ”។*

## ខ. ការមានផ្ទៃពោះដោយបង្ខំជាផ្នែកមួយនៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត”

24. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះដូចខាងក្រោម លើកឡើងថា ឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្នុងទម្រង់ជា “អំពើអមនុស្សធម៌ផ្សេងៗទៀត”។ ឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំបំពេញលក្ខខណ្ឌតម្រូវនៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត” ហើយដូច្នេះ វាស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

## I. ធាតុផ្សំទូទៅនៃការមានផ្ទៃពោះដោយបង្ខំដែលជាផ្នែកមួយនៃអំពើអមនុស្សធម៌ផ្សេងៗទៀត

25. ដូចមានចែងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសាលក្រមសំណុំរឿង ០០២/០១[36] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត” តម្រូវឱ្យមានធាតុផ្សំទូទៅដូចខាងក្រោម៖

*ក) “អំពើអមនុស្សធម៌ផ្សេងៗទៀត” គឺជាអំពើសកម្ម ឬអកម្មរបស់ជនជាប់ចោទ ឬអ្នកនៅក្រោមបង្គាប់របស់ខ្លួន៖*

*(i) ដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្ត ឬបង្កឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង*

*(ii) ដែលបានប្រព្រឹត្តឡើងដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើជនរងគ្រោះដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ។*

[36] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ,, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៧-៤៣៨។

*ខ) អំពើសកម្ម ឬអកម្ម ត្រូវតែមានលក្ខណៈ និងមានស្ថានទម្ងន់ ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ផ្សេងទៀត។ ភាពធ្ងន់ធ្ងរនៃអំពើនេះ គឺត្រូវបានវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាលើកាលៈទេសៈរបស់បុគ្គលនីមួយៗនៅក្នុងរឿងក្តីនោះ។*

លើលពីនេះទៀត ការប្រព្រឹត្តនោះត្រូវតែបំពេញលក្ខខណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ អំពើអមនុស្សធម៌ត្រូវតែបានប្រព្រឹត្តិឡើងជាផ្នែកមួយនៃ *"វាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ"*[37]។

(១) <u>បណ្តាលឲ្យមានព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្ត ឬបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ</u>

26. ការប្រព្រឹត្តិដែលមានវិវាទត្រូវតែមានទង្វើបង្កឲ្យមានព្យសនកកម្មធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្ត ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ អង្គហេតុនានាដែលបានបង្ហាញនៅក្នុងកថាខណ្ឌខាងក្រោម នឹងបង្ហាញថាតើហេតុអ្វីបានជាការមានផ្ទៃពោះរបស់ស្ត្រីដូចដែលបានកើតមានក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម បំពេញលក្ខខណ្ឌ តម្រូវនេះ។

27. ជាចំណុចចាប់ផ្តើម ការមានផ្ទៃពោះស្ថិតក្រោមកាលៈទេសៈដែលបានពិពណ៌នាខាងលើ ត្រូវតែវែកញែកឲ្យដាច់ស្រឡះពីការមានផ្ទៃពោះស្ថិតក្រោមកាលៈទេសៈធម្មតា។ ដោយសារជាភាពចាំបាច់ផ្នែកជីវសាស្ត្រ ការមានផ្ទៃពោះ និងការបង្កើតកូន ជានិច្ចកាលទទួលរងការឈឺចាប់មួយចំនួន រោគសញ្ញាវេជ្ជសាស្ត្រ និងទុក្ខលំបាកផ្នែករាងកាយបណ្តោះអាសន្នសម្រាប់ស្ត្រី ដែលផ្តល់កំណើតដល់កូន។ ហេតុដូចនេះ ការពិចារណានេះនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការឈឺចាប់ និងការរងទុក្ខពាក់ព័ន្ធនឹងការមានផ្ទៃពោះ ប្រសិនបើការឈឺចាប់ និងការរងទុក្ខនោះកើតមានឡើងលើសពីផលវិបាកនៃការមានផ្ទៃពោះធម្មតា និងលទ្ធផលនានាដែលកើតចេញពីកាលៈទេសៈជាក់លាក់ក្នុងរបបខ្មែរក្រហម។

[37] មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

28. លើសពីនេះទៀត ប្រការត្រូវផ្ដោតការយកចិត្តទុកដាក់នោះគឺថា កូនដែលបានកើតពីការមានផ្ទៃពោះបែបនេះ មិនត្រូវបានចាត់ទុកថាជាព្យសនកម្ម ឬផលវិបាកខុសពីបំណងប្រថ្នាឡើយ។ កត្តានានាដែលត្រូវពិចារណាដើម្បីកំណត់អំពីវិសាលភាពនៃព្យសនកម្មនោះ គឺស្ថានភាពរបស់ជនរងគ្រោះក្នុងអំឡុងពេលមានផ្ទៃពោះ កាលៈទេសៈនៃការតាំងគភ៌ ការបង្កើតកូន និងលទ្ធផលក្រោយបង្កើតកូន។

ក. ស្ថានភាពធ្ងន់ធ្ងរក្នុងអំឡុងពេលមានផ្ទៃពោះ

29. តថភាពនៃការមានផ្ទៃពោះស្ថិតក្រោមការបង្ខិតបង្ខំពីសំណាក់របបខ្មែរក្រហម មានន័យថាជាការអត់ទ្រាំទុក្ខលំបាករយៈពេលប្រាំបួនខែនៃការផ្លាស់ប្ដូររាងកាយរបស់មនុស្សម្នាក់ ក្នុងអំឡុងពេលមួយដែលប្រជាជនកម្ពុជាភាគច្រើនត្រូវបានបង្ខំឲ្យធ្វើការយ៉ាងលំបាកវេទនា ហើយទទួលរងនូវអំពើហិង្សាលើរាងកាយ ខណៈពេលដែលគ្មានអាហារ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រគ្រប់គ្រាន់។ ទាំងអស់នេះគឺជាកត្តាដែលនាំឲ្យមានបរិយាកាសនៃការធ្វើទុកបុកម្នេញលើស្ត្រីមានផ្ទៃពោះ។

30. ក្នុងបរិបទនេះ ការក្លាយខ្លួនជាស្ត្រីមានផ្ទៃពោះគឺជាភាពភ័យខ្លាចជាប្រចាំរបស់ស្ត្រី[38]។ អ្នកចូលរួមម្នាក់ក្នុងគម្រោងប្រវត្តិរឿងផ្ទាល់មាត់របស់ Theresa de Langis ពិពណ៌នាអំពីផលវិបាកដែលស្ត្រីបានជួបប្រទះ នៅពេលពួកគេមានផ្ទៃពោះដូចខាងក្រោម៖

> *"ស្ត្រីមានផ្ទៃពោះ ហើមជើង និងប្រអប់ជើងខ្លាំង ដោយមានស្នាមរយៈ និងក្រមំ ដោយសារការធ្វើការនៅក្នុងវាលស្រែ។ ស្ត្រីមានផ្ទៃពោះមួយចំនួនឡើងហើម ដោយសារកង្វះអាហារូបត្ថម្ភមូលដ្ឋាន ដូចជា អំបិល និងស្ករ។ ខ្មែរក្រហមមិនបានថែទាំសុខភាពរបស់ស្ត្រីមានផ្ទៃពោះទេ។ ពួកគេយកចិត្តទុកដាក់តែលើការបង្ខំឲ្យមនុស្សគ្រប់គ្នាធ្វើការ និងគោរពបទបញ្ជាតែប៉ុណ្ណោះ"[39] ។*

---

[38] Theresa de Langis, Judith Strasser, Thida Kim, Sopheap Taing, *"ដូចខ្មោចប្រែកាឡាខ្លួន៖ ការសិក្សាពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម"*, អង្គការចិត្តសង្គម អន្តរវប្បធម៌ (ឆ្នាំ២០១៤), ទំព័រ ៨០, ភ្ជាប់ជាឧបសម្ព័ន្ធ ១២។

[39] Theresa de Langis, *"គម្រោងប្រវត្តិរឿងផ្ទាល់មាត់របស់ស្ត្រីកម្ពុជា៖ រឿងរ៉ាវជីវិតនៃការរស់រានក្នុងរបបខ្មែរក្រហម"*, បទសម្ភាសជាមួយ សុក សាមិត្ត (Sok Samith) (ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៣), ភ្ជាប់ជាឧបសម្ព័ន្ធ ១៣។

31. អ្នកចូលរួមទាំងអស់នៅក្នុងការស្រាវជ្រាវដ៏ទូលំទូលាយមួយ ដែលត្រូវបានរៀបចំឡើងដោយ Kasumi Nakagawa ស្តីពីការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម បានរាយការណ៍ថា ពួកគេមិនរីករាយនោះទេក្នុងអំឡុងពេលមានផ្ទៃពោះនៅក្នុងរបប "កម្ពុជាប្រជាធិបតេយ្យ"។ ពួកគេមិនចង់មានផ្ទៃពោះនោះឡើយ[40]។ ការណ៍នេះត្រូវបានបញ្ជាក់ដោយការផ្តល់សក្ខីកម្មរបស់សាក្សីមួយរូបក្នុងសំណុំរឿង ០០២ ដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងរបបនេះ ហើយក្រោយមកបានមានផ្ទៃពោះ៖

> *"មានផ្ទៃពោះពីរបីខែអ៊ីចឹង ខ្ញុំគេឱ្យ សហករណ៍ គេឱ្យដើររើសអាចម៍គោ រែកដីដំបូកអ៊ីចឹង ចាក់ស្រែចាក់អ៊ីចឹង ដើររើសអាចម៍គោហ្នឹង ដើរថ្ងឹង មួយថ្ងៃបានប៉ុន្មានគីឡូ បើបានតិចតួចៗ គេកសាងយើង។ ហើយម្យ៉ាងខ្ញុំហូបបាយ វាចាញ់កូនផង ហូបបាយអត់កើត ឈឺឡើងស្គមអ៊ីចឹង ហើយសាច់ឡើងស្លេក។ ទៅរើសអាចម៍គោអ៊ីចឹងទៅ ហើយទៅរែកដីអ៊ីចឹងទៅ បន្តិចៗគេប្រជុំអ៊ីចឹង គេកសាងយើងហើយ។ គេថាយើងនឹងធ្វើសតិអារម្មណ៍ខ្ជិលធ្វើការងារ។ ដល់ទៅរែកតែដីដំបូកហ្នឹង ពង្រាយស្រែហ្នឹង រែកហ្នឹងក្តួតផង ហើយដល់ពេលបាយហ្នឹង ហូបបាយអត់កើតទេ ទឹកសម្លក៏ហូបមិនបាន ខ្ញុំហូបតែជាមួយអំបិលៗ ស្រួបទឹកអំបិលៗស្រួបទឹកអ៊ីចឹងទៅ។ ដល់ពេលទៅធ្វើការអីអ៊ីចឹង ទៅធ្វើអត់កើតអ៊ីចឹង គេចេះតែថាយើងហ្នឹងពេលៗនេះប្រធានកងគេមកស្តីយើងហើយ។ គេបន្តិចៗគេមកស្តីអ៊ីចឹងទៅ គេថាយើងសតិអារម្មណ៍។ ពេលបើកអង្គប្រជុំថ្ងៃ ខែ -- ថ្ងៃ១០ៗ ថ្ងៃ២០ ថ្ងៃ៣០ អ៊ីចឹងគេប្រជុំកងហើយ គេប្រជុំក្រុមទិតៀនគ្នា។ គេលើកគ្នាទិតៀនតែខ្ញុំហ្នឹង គេថា ខ្ញុំហ្នឹងសតិអារម្មណ៍ ខ្ជិលធ្វើការទម្រន់អី"[41]*។

32. ស្ត្រីមានផ្ទៃពោះ បានរស់នៅក្រោមស្ថានភាពរស់នៅដ៏លំបាកខ្លាំងក្នុងអំឡុងពេលមានផ្ទៃពោះ ពេលបង្កើតកូន និងក្រោយបង្កើនកូនរបស់ពួកគេ។ ស្ត្រីដែលមានផ្ទៃពោះត្រូវតែស៊ូទ្រាំទៅនឹងការងារ

---

[40] Nakagawa Kasumi, *ភាពជាម្តាយនៅពេលមានសង្គ្រាម - ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម (ប្រវត្តិផ្ទាល់មាត់)*, ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៩, ភ្ជាប់ជាឧបសម្ព័ន្ធ ១៤។

[41] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E1/254.1**, *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីដំណាក់កាលទីពីរ*, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥, *សវនាការលើកទី ២៣៥*, ទំព័រ ៣៨, ភ្ជាប់ជាឧបសម្ព័ន្ធ ១៥។

លំបាកដូចគ្នានឹងស្ត្រីគ្មានផ្ទៃពោះផ្សេងៗទៀតដូច្នេះដែរ[42]។ ពួកគេត្រូវបានរំពឹងថានឹងបន្តធ្វើការរហូតពេញមួយរយៈពេលមានផ្ទៃពោះ ហើយក្រោយមកត្រលប់ទៅធ្វើការងារធ្ងន់ភ្លាមៗបន្ទាប់ពីបង្កើតកូន[43]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ បានមានផ្ទៃពោះក្នុងឆ្នាំ ១៩៧៨ ហើយបានពិពណ៌នាអំពីការដែលមិនអាចឈប់សម្រាកក្នុងអំឡុងពេលមានផ្ទៃពោះ។ គាត់ត្រូវបានបង្ខំឱ្យធ្វើការដោយគ្មានឈប់សម្រាក ឬមិនឱ្យបរិភោគអាហារគ្រប់គ្រាន់រហូតដល់ពេលសម្រាលកូន[44]។ វាជាវាសនាទូទៅរបស់ស្ត្រីដែលមានផ្ទៃពោះស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ដោយពួកគេមិនទទួលបានការថែរក្សា ឬថែទាំនោះឡើយ[45]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ផ្សេងទៀត ពិពណ៌នាអំពីភាពលំបាកដែលគាត់ត្រូវអត់ទ្រាំដូចខាងក្រោម៖

> *"អំឡុងពេលមានកូននេះគឺពិបាកណាស់ដោយសារខ្ញុំចាញ់កូនរហូត ហើយត្រូវខំធ្វើការឱ្យគេទៀត ដោយឈរចៀរជ័រ គ្មានពេលសម្រាកទេ ពេលនោះខ្ញុំមានទម្ងន់ប្រាំពីរខែ ហើយកូននោះមិនបម្រះ ខ្ញុំបានប្រាប់ទៅគេ តែគេមិនបានឱ្យខ្ញុំឈប់សម្រាកនោះ គឺឱ្យធ្វើការរហូតដល់ថ្ងៃកើត"*[46]។

ខ. កង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងមរណៈភាពកុមារ

---

[42] Nakagawa Kasumi, *ភាពជាម្ដាយនៅពេលមានសង្គ្រាម - ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម (ប្រវត្តិផ្ទាល់មាត់)*, ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៥៦-៥៧។

[43] Peg LeVine, *"ក្ដីស្រលាញ់ និងភាពភ័យខ្លាចនៅកម្ពុជា។ អាពាហ៍ពិពាហ៍ កំណើត និងព្យសនកម្មវិធីក្នុងរបបខ្មែរក្រហម"* (ឆ្នាំ ២០១០), ទំព័រ ៧២, ភ្ជាប់ជាឧបសម្ព័ន្ធ ១៦។ ឡឿក សំ, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*, ឯកសារ **D5/1172**, ទំព័រ ៣។ Nakagawa Kasumi, *ភាពជាម្ដាយនៅពេលមានសង្គ្រាម - ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម (ប្រវត្តិផ្ទាល់មាត់)*, ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៥៥។ ឡុង សារីន, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*, ឯកសារ **D5/1292**, ទំព័រ ៦-៧។

[44] ជួន ណារី, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*, ឯកសារ **D5/1335**, ទំព័រ ៣។

[45] អោម ពៅ, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*, ឯកសារ **D5/1168**, ទំព័រ ៣។

[46] អ៊ុំ យឿន, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*, ឯកសារ **D5/1166**, ទំព័រ ៣។

33. ស្ត្រីមានផ្ទៃពោះភាគច្រើនមិនអនុញ្ញាតឱ្យទទួលបានការព្យាបាលផ្នែកវេជ្ជសាស្ត្រណាមួយនោះឡើយ ឬពេលខ្លះទទួលបានតិចតួចបំផុតក្នុងអំឡុងពេលមានផ្ទៃពោះ ឬបន្ទាប់ពីសម្រាលកូន[47]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ បានពិពណ៌នាអំពីអ្វីដែលបានកើតឡើងនៅពេលគាត់បានស្នើសុំថ្នាំពេទ្យសម្រាប់កូនរបស់គាត់ដែលឈឺដូចខាងក្រោម៖

> *"ពីរខែក្រោយពីខ្ញុំសម្រាលកូនទី២ រួច ខ្ញុំបានទៅសុំថ្នាំ [...] គាត់សួរខ្ញុំថា "ហេតុអ្វីបានជាខ្ញុំត្រូវព្យាបាលកូនឯាំង"។ គាត់ប្រាប់ខ្ញុំឱ្យទុកកូននោះឱ្យស្លាប់ទៅ[...]"។"[48]* ។

34. បើទោះជាបន្ទាប់ពីកូនបានកើតហើយក្តី ទាំងម្តាយ និងកូនកម្រទទួលបានការព្យាបាលផ្នែកវេជ្ជសស្ត្រណាស់។ ទារកយ៉ាងច្រើននឹងស្លាប់ បន្ទាប់ពីកើតដោយសារជំងឺ កង្វះថ្នាំ ឬការបាក់កម្លាំងកាយរបស់ម្តាយដែលមិនអាចបំបៅដោះ[49]។ ម្តាយម្នាក់ដែលស្ថិតនៅក្នុងមន្ទីរឃុំឃាំងក្នុងអំឡុងពេលមានផ្ទៃពោះ បានពន្យល់ថា៖ "វេទនាជាទីបំផុត មិនមានអាហារបរិភោគគ្រប់គ្រាន់ ឈឺគ្មានថ្នាំព្យាបាល គ្មានពេទ្យមើលថែទាំ"[50]។

## គ. ព្យសនកម្មផ្លូវចិត្ត

35. ព្យសនកម្មដែលស្ត្រីមានផ្ទៃពោះទទួលរង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះមានទំហំធំធេងជាងការងារពលកម្មដោយបង្ខំ ឬអំពើហិង្សាដែលអាចប្រមើលមើលបាន[51]។ ការមានផ្ទៃពោះមានផលប៉ះពាល់អវិជ្ជមានលើសុខភាពផ្លូវចិត្តរបស់ស្ត្រីផងដែរ។ យោងតាមការអង្កេតមួយដែលត្រូវបានធ្វើឡើងដោយ Peg LeVine ស្ត្រីជាច្រើនមិនត្រូវបានផ្តល់អាហារ ឬឈប់សម្រាកគ្រប់គ្រាន់នោះឡើយក្នុងអំឡុងពេលមានផ្ទៃពោះ ដែលបានបង្កឱ្យមានអារម្មណ៍ភ័យខ្លាចថា ពួកគេនឹងមិន

---

[47] Nakagawa Kasumi, *ភាពជាម្តាយនៅពេលមានសង្គ្រាម - ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម (ប្រវត្តិផ្ទាល់មាត់)*, ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៥៨។

[48] ស៊ុំ ចាន់ថុល, កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/472**, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥, ទំព័រ ៦។

[49] ពៅ ឈុនឡេង, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/1165**, ទំព័រ ៣។ ឡុង ស៊ឹម, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/1292**, ទំព័រ ៦-៧។

[50] អ៊ូម ម៉ុន, *ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/296**, ទំព័រ ២។

[51] María Lobato, "ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម", (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ១៦។

អាចបំបៅដោះកូនរបស់ពួកគេបានសមរម្យឡើយ[52]។ ពិធីនានាដែលត្រូវបានរៀបចំធ្វើឡើងជាប្រពៃណីក្នុងអំឡុង និងបន្ទាប់ពីសម្រាលកូន ត្រូវបានហាមឃាត់។ ការអាក់ខានផ្នែកវប្បធម៌នេះត្រូវបានកំណត់ថាជាបុព្វហេតុនៃ "ភាពភ័យខ្លាចខាងស្មារតី" និងឧបសគ្គនៃការវិវត្តរាងកាយ[53]។

36. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់រៀបរាប់អំពីរបៀបដែលគាត់ និងកូនស្រីរបស់គាត់ទទួលរងនូវអារម្មណ៍ថាសង្គមមិនផ្តល់តម្លៃឱ្យដោយសារបញ្ហាដែលថា កូនស្រីរបស់គាត់បានកើតពីចំណងអាពាហ៍ពិពាហ៍ដោយបង្ខំ[54]៖

> *"នៅពេលយើងបែកគ្នា ខ្ញុំមានផ្ទៃពោះ ២ខែ។ ឥឡូវកូនស្រីរបស់ខ្ញុំមានអាយុ ៣៥ ឆ្នាំហើយ។ កូនស្រីរបស់ខ្ញុំដឹងថា ខ្ញុំត្រូវបានបង្ខំឱ្យរៀបការ។ នាងមានអារម្មណ៍ឈឺចាប់អំពីរឿងនេះ។ ប្រជាជនមើលងាយទាំងកូន និងឪពុកម្តាយ ដែលរងការបង្ខំឱ្យរៀបការ"។*

## ឃ. ការរម្លូតកូនដោយគ្មានសុវត្ថិភាព

37. ព្យសនកម្មជាក់លាក់នៃការមានផ្ទៃពោះ រួមមាន បទពិសោធរបស់ស្ត្រីដែលបានពិចារណាអំពីការរម្លូតកូន ឬមិនទុកឱ្យកូនរបស់ពួកគេរហូតដល់កើត[55]។ មនុស្សដែលរស់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាញឹកញាប់រស់នៅក្នុងការឃុំឃាំងខ្លួនជាអចិន្ត្រៃយ៍ ដែលបាត់បង់អស់សេរីភាពរាងកាយរបស់ខ្លួន រួមទាំងសិទ្ធិទទួលបានសេវាសុខភាពផងដែរ[56]។ ស្ថិតក្រោមកាលៈទេសៈទាំងនេះ ស្ត្រីដែលមានផ្ទៃពោះដោយបង្ខំមិនមានមធ្យោបាយប្រកបដោយសុវត្ថិភាពដើម្បីរម្លូតកូនដែលមិនចង់បានរបស់ខ្លួនទេឡើយ។ ជនរងគ្រោះម្នាក់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលក្រោយមកមានផ្ទៃពោះ បានថ្លែងថា៖

---

[52] Peg LeVine, *"ក្តីស្រលាញ់ និងភាពភ័យខ្លាចនៅកម្ពុជា។ អាពាហ៍ពិពាហ៍ កំណើត និងព្យសនកម្មពិធី ក្នុងរបបខ្មែរក្រហម"* (ឆ្នាំ ២០១០) , ទំព័រ ៧២។

[53] María Lobato, "*ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម*", (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ១៨។

[54] ថន យ៉ង់, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D219/136**, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤, ទំព័រ ១៥។

[55] Nakagawa Kasumi, *ភាពជាម្តាយនៅពេលមានសង្គ្រាម - ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម (ប្រវត្តិផ្ទាល់មាត់)*, ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៧៣។

[56] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ឯកសារ **D427**, *ដីកាដំណោះស្រាយ*, កថាខណ្ឌ ១៥៨, ១៧៧, ២២២, ៣១៣។

*“ប្រសិនបើខ្ញុំចង់រំលូតកូន តើខ្ញុំអាចធ្វើដូចម្តេច? ខ្ញុំខ្លាចអង្គការដឹង ហើយគ្មានវេជ្ជបណ្ឌិត គ្មានថ្នាំសម្រាប់ទប់ស្កាត់ការមានកំណើតទេ”*[57] ។

38. ហេតុដូច្នេះ ស្ត្រីមួយចំនួនបានព្យាយាមរំលូតកូនដោយខ្លួនឯង ដោយប្រើប្រាស់វិធីសាស្ត្រដែលគ្មានសុវត្ថិភាព ដែលប្រឈមនឹងហានិភ័យដ៏ធំធេងមួយមកលើខ្លួន ហើយជាញឹកញាប់បានស្លាប់[58]។ ស្ត្រីមួយចំនួនបានពិពណ៌នាអំពីនីតិវិធីប្រកបដោយគ្រោះថ្នាក់ទាំងនេះ ដូចជា យកផាងត្នោតមកវះពោះ ឬលោតចុះពីទីខ្ពស់ជាដើម[59]។ ព្យសនកម្មនេះត្រូវបានលើកយកមកបង្ហាញនៅក្នុងការផ្តល់សក្ខីកម្មរបស់អ្នកចូលរួមម្នាក់នៅក្នុងសវនាការរបស់ស្ត្រីនៅឆ្នាំ ២០១២។ ប្អូនស្រីរបស់ស្ត្រីនោះត្រូវបានបង្ខំឱ្យរៀបការ និងរួមដំណេកដែលធ្វើឱ្យគាត់មានផ្ទៃពោះ ហើយនៅពេលគាត់មិនចង់ទុកកូននោះ ស្ត្រីរូបនោះបានជួយប្អូនរបស់គាត់រំលូតកូនតាមរយៈការដាល់លើពោះរបស់គាត់ និងរមៀលខ្លួនពីទួលមួយ[60]។

ង. ការរលូតកូនញឹកញាប់

39. ដោយសារផលវិបាកនៃស្ថានភាពលំបាកទាំងនេះ អត្រាកូនកើតស្លាប់ និងរលូតកូនមានកម្រិត ខ្ពស់ដែលកាន់តែបង្កឱ្យមានការភ័យតក់ស្លុតសម្រាប់ស្ត្រីដែលមានផ្ទៃពោះថែមទៀត[61]។ ការសិក្សាមួយបានរកឃើញថា ស្ត្រីម្នាក់ក្នុងចំណោម ៧០ នាក់ដែលមានផ្ទៃពោះក្នុងបរិបទនៃការរៀបអាពាហ៍

---

[57] Theresa de Langis, Judith Strasser, Thida Kim, Sopheap Taing,*“ដូចខ្មោចប្រែកាឡាខ្លួន៖ ការសិក្សាពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម”*, អង្គការចិត្តសង្គម អន្តរវប្បធម៌ (ឆ្នាំ២០១៤), ទំព័រ ៨០។

[58] Judith Strasser, Thida Kim, Silke Studzinsky, Sopheap Taing, *ការសិក្សាពីការចូលរួមរបស់ជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម*, អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (ខែ កញ្ញា ឆ្នាំ ២០១៥), ទំព័រ ៧៨, ភ្ជាប់ជាឧបសម្ព័ន្ធ ១៧។

[59] Judith Strasser, Thida Kim, Silke Studzinsky, Sopheap Taing, *ការសិក្សាពីការចូលរួមរបស់ជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម*, អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (ខែ កញ្ញា ឆ្នាំ ២០១៥), ទំព័រ ៧៨។

[60] Theresa de Langis, *សវនាការរបស់ស្ត្រីប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកស្តីពីអំពើហិង្សាយេនឌ័រដែលស្ថិតក្នុងជម្លោះ - របាយការណ៍ស្តីពីកិច្ចដំណើរការនីតិវិធី ឆ្នាំ ២០១២*, ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (ឆ្នាំ ២០១២), ទំព័រ ១៦, ភ្ជាប់ជាឧបសម្ព័ន្ធ ១៨។

[61] Nakagawa Kasumi, *ភាពជាម្តាយនៅពេលមានសង្គ្រាម - ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម (ប្រវត្តិផ្ទាល់មាត់)*, ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៨១។

ពិពាហ៍ដោយបង្ខំ ក្នុង ១១ ករណី ទារកបានស្លាប់នៅពេលកើត ហើយ ៦ រម្លូតដោយឥតគ្រោងទុក[62]។ ស្ត្រីម្នាក់មកពីខេត្តតាកែវ ត្រូវបានបង្ខំឱ្យរៀបការជាមួយអតីតព្រះសង្ឃម្នាក់។ បន្ទាប់ពីការរួមភេទដោយបង្ខំរួចមក គាត់បានរម្លូតកូនដែលឥតគ្រោងទុក គ្មានសុវត្ថិភាព និងកូនកើតស្លាប់ដោយគ្មានជំនួយណាមួយឡើយ[63]។ ស្ត្រីម្នាក់ផ្សេងទៀត ដែលជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានឃុំឃាំងក្នុងអំឡុងពេលមានផ្ទៃពោះ និងពិពណ៌នាអំពីការមិនទទួលបានអាហារគ្រប់គ្រាន់ និងកង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ។ គាត់ត្រូវបានគេដាក់ខ្នោះជាមួយអ្នកទោសផ្សេងទៀតទាំងថ្ងៃទាំងយប់ ហើយ "ត្រូវបានបង្ខំឱ្យធ្វើការ សូម្បីតែនៅពេលខ្ញុំជាប់ខ្នោះ"។ គាត់បានពិពណ៌នាអំពីការរលូតកូនរបស់គាត់ បន្ទាប់ពីគាត់បានធ្លាក់ចូលក្នុងវាលស្រែ ខណៈពេលដែលចេញពីធ្វើការនៅថ្ងៃមួយ[64] ដូចខាងក្រោម៖

> *"ឈាមហូរក្រហមពេសពេញស្រែ គេក៏បណ្តើរមកដាក់គុក [...] ហើយនៅក្នុងគុកបន្តរហូតមិនបានយកនាងខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យទេ"។*

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ផ្សេងទៀត រាយការណ៍អំពីរបៀបដែលគាត់ត្រូវបានបង្ខំឱ្យធ្វើដំណើរឆ្លងទន្លេមួយ ខណៈពេលដែលគាត់មានផ្ទៃពោះ។ គាត់បានដួល ដែលបណ្តាលឱ្យកូនរបស់គាត់ស្លាប់[65]។ ការណ៍នេះរៀបរាប់បន្ថែមអំពីព្យសនកម្មដែលស្ត្រីបានរងគ្រោះនៃការមានផ្ទៃពោះដោយបង្ខំ ដែលមិនអាចពពោះរហូតដល់កូនកើត។

40. បើទោះជាស្ត្រីអាចផ្តល់កំណើតដល់កូនរបស់ពួកគេបានក៏ដោយ ក៏គ្រោះថ្នាក់របស់ម្តាយ និងកូនដោយសារស្ថានភាពភាពធ្ងន់ធ្ងរ និងកង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ បានបន្តកើតមាន។ អ្នកដាក់

---

[62] María Lobato, "*ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម*", (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ១៨។

[63] Peg LeVine, "*ក្តីស្រលាញ់ និងភាពភ័យខ្លាចនៅកម្ពុជា។ អាពាហ៍ពិពាហ៍ កំណើត និងព្យសនកម្មវិតិក្នុងរបបខ្មែរក្រហម*" (ឆ្នាំ ២០១០), ទំព័រ ១៣០។

[64] អ៊ូម ម៉ុន, *ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/296**, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩, ទំព័រ ២។

[65] ឈិន ម៉េត, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ*, ឯកសារ **D5/529**, ទំព័រ ៣។ ពីព័ត៌មានដែលអាចរកបានក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះនេះ មិនមានភាពច្បាស់លាស់នោះទេថាតើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានផ្ទៃពោះដោយសារតែអាពាហ៍ពិពាហ៍ដោយបង្ខំឬយ៉ាងណានោះ។ ទោះជាយ៉ាងណា ករណីរបស់គាត់គឺជាឧទាហរណ៍បែបបង្ហាញមួយ ដើម្បីបង្ហាញអំពីការព្យាបាលស្ត្រីមានផ្ទៃពោះក្នុងរបបខ្មែរក្រហម។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ពិពណ៌នាអំពីរបៀប ដែលកូនរបស់គាត់បានស្លាប់មុនពេលមានអាយុ ៦ ខែ ពីព្រោះគាត់មិនមានទឹកដោះគ្រប់គ្រាន់ឱ្យកូនគាត់បៅ[66]។

ច. សេចក្តីសន្និដ្ឋាន

41. ដោយផ្អែកលើការពិចារណាទាំងនេះ គោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានអនុវត្តក្នុងរបបខ្មែរក្រហម បានធ្វើឱ្យស្ត្រីដែលជាជនរងគ្រោះពីការមានផ្ទៃពោះ ទទួលរងនូវព្យសនកម្មផ្នែករូបរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ។

(២) <u>បានប្រព្រឹត្តឡើងដោយចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើជនរងគ្រោះដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ។</u>

42. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ បញ្ជាក់ថា សហព្រះរាជអាជ្ញាមានហេតុផលដែលនាំឱ្យជឿបានថា [redacted] អោ អាន បានប្រព្រឹត្ត បានរៀបចំផែនការ បានញុះញង់ បានបញ្ជា ឬបានជួយ និងទំនុកបម្រុងឱ្យមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានបង្កឱ្យមានផ្ទៃពោះឥតគ្រោងទុក[67]។ ហេតុដូច្នេះហើយបានជាមានការរៀបរាប់ដូចខាងលើអំពីចេតនាដែលចាំបាច់ក្នុងការបង្កឱ្យមានព្យសនកម្ម។

(៣) <u>ស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងបទល្មើសជាក់លាក់ផ្សេងទៀត</u>

43. បទល្មើសដែលបង្កើតបានជាឧក្រិដ្ឋកម្មមួយស្ថិតក្រោមប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវតែមានស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងបទល្មើសជាក់លាក់ផ្សេងទៀត ដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញពី លក្ខណៈវិនិច្ឆ័យមួយចំនួនដូចខាងក្រោម៖

> *"ដើម្បីបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" លក្ខណៈ និងស្ថានទម្ងន់នៃបទល្មើស ឬអំពើអកម្មនានា ត្រូវមានសណ្ឋានប្រហាក់ប្រហែលគ្នាគ្រប់គ្រាន់ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលអាចវាយតម្លៃដោយផ្អែកតាមករណីនីមួយៗដោយ*

---

[66] ឡុង សារីន, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/1292**, ទំព័រ ៦-៧។

[67] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤,ឯកសារ**D191**, កថាខណ្ឌ ១៤។

*ពិចារណាទៅលើលក្ខណៈនៃអំពើបរិបទកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ព្រមទាំងផលប៉ះពាល់ផ្នែកសីលធម៌ ផ្នែកផ្លូវកាយ និងផ្លូវចិត្តមកលើជនរងគ្រោះ រួមទាំងផលប៉ះពាល់រយៈពេលយូរ"*[68]។

44. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម ដែលបានបង្កឱ្យមានផ្ទៃពោះឥតគ្រោងទុក ចាត់ចូលក្នុងលក្ខណៈវិនិច្ឆ័យនេះ។ នៅពេលវាយតម្លៃស្ថានទម្ងន់នៃការមានផ្ទៃពោះដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ គេត្រូវពិចារណាថា អាពាហ៍ពិពាហ៍ទាំងនោះត្រូវបានរៀបចំឡើងក្នុងបរិបទនៃរបបគៀបសង្កត់ ដែលដាក់ឱ្យប្រជាជនកម្ពុជាភាគច្រើនអនុវត្តគោលនយោបាយខុសច្បាប់ និងគោលនយោបាយឧក្រិដ្ឋកម្មជាច្រើន[69]។ ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវប្រឈមយ៉ាងធ្ងន់ធ្ងរទៅនឹងភាពតានតឹងផ្សេងទៀត ដូចជាការធ្វើការបាក់កម្លាំង កង្វះអាហារូបត្ថម្ភ ឬការដាក់ពន្ធនាគារសូម្បីតែមុនពេលពួកគេមានផ្ទៃពោះ។ ព្យសនកម្មដែលពួកគេទទួលរងក្នុងអំឡុងពេលពរពោះរយៈពេល ៩ ខែ គឺជាការលំបាកបន្ថែមទៀតចំពោះស្ថានភាពអមនុស្សរបស់ជនរងគ្រោះ។ ស្ថានទម្ងន់នៃគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរ ដោយសារតែបរិបទរបស់វា។

45. លើសពីនេះទៀត លក្ខណៈនៃអំពើដែលបង្កឱ្យមានផ្ទៃពោះ គឺជាការបំពានធ្ងន់ធ្ងរលើស្ថានភាពផ្ទាល់ខ្លួនរបស់ស្ត្រី។ ពាក់ព័ន្ធនឹងបុរេលក្ខខណ្ឌចាំបាច់នៃការមានផ្ទៃពោះ ជនរងគ្រោះទាំងអស់ត្រូវរួមភេទដែលស្ថិតក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលភាគច្រើនគ្មានការស្ម័គ្រចិត្ត និងធ្វើឡើងក្នុងស្ថានភាពបង្ខិតបង្ខំ ពោលគឺស្ថិតក្រោមការគំរាមកំហែងពីការលួចតាមដានពីសំណាក់កម្មាភិបាលខ្មែរក្រហម និងការភ័យខ្លាចការសងសឹក ប្រសិនបើពួកគេមិនបានរួមដំណេក[70]។ ក្នុង

---

[68] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E188**, *សាលក្រម*, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៧-៣៦៩, ភ្ជាប់ជាឧបសម្ព័ន្ធ១៩។ អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខ័ណ្ឌ ៤៣៨។

[69] *សូមមើល* ការបរិយាយក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ឯកសារ **D1**, កថាខ័ណ្ឌ ៦-៨។

[70] *សូមមើល* ឧទាហរណ៍៖ កែវ ធារី, *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/113**, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤, ទំព័រ ១១-១៣, ១៦។ សិន បាន, *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/306**, ថ្ងៃទី ៨ *សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំឱ្យមានកិច្ចស៊ើបសួរប្រឆាំង អោ អាន* [redacted] *ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ*

ករណីជាច្រើន ជនរងគ្រោះ ដែលទើបតែបានរៀបអាពាហ៍ពិពាហ៍ថ្មីៗ ត្រូវបានរងការរំលោភសេពសន្ថវៈពីសំណាក់ប្តីរបស់ខ្លួន[71]។ ហេតុដូច្នេះ លក្ខណៈនៃការមានផ្ទៃពោះដោយបង្ខំ ពិតជាបង្កប់អំពើរំលោភសេពសន្ថវៈ ដែលជាស្ថានទម្ងន់នៃសកម្មភាពនេះ។

46. ក្រៅពីលក្ខណៈធ្ងន់ធ្ងរនៃអំពើនេះ និងបរិបទរបស់វា ផលវិបាកធ្ងន់ធ្ងរជាច្រើនដែលជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវប្រឈម មានបង្ហាញក្នុងផ្នែកខាងលើ។ ស្ថានភាពលំបាកក្នុងពេលពរពោះ កង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការលំបាកផ្សេងទៀត ដូចជាការរលូតកូនញឹកញាប់ និងការរម្លូតកូនដោយគ្មានសុវត្ថិភាព មិនត្រឹមតែបានជះឥទ្ធិពលអាក្រក់ធ្ងន់ធ្ងរលើជនរងគ្រោះក្នុងអំឡុងពេលពរពោះរយៈពេល ៩ ខែប៉ុណ្ណោះទេ តែថែមទាំងបានបង្កឲ្យមានព្យសនកម្មលើរូបរាងកាយ និងផ្លូវចិត្តរយៈពេលវែងលើជនរងគ្រោះទៀតផង។ ព្យសនកម្មភាគច្រើននៅបន្តកើតមានរហូតមកទល់សព្វថ្ងៃនេះ[72]។

47. ដើម្បីវាយតម្លៃភាពស្រដៀងគ្នា និងស្ថានទម្ងន់នៃបទល្មើសដ៏ចម្រូងចម្រាស់នេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY)[73] បានសំអាងលើបទដ្ឋានដែលបង្កើតឡើងក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ក្នុងបរិបទបច្ចុប្បន្ន ច្បាប់សិទ្ធិមនុស្សមានភាពពាក់ព័ន្ធខ្លាំងទៅនឹងសិទ្ធិបន្តពូជ។ នៅដើមឆ្នាំ ១៩៦៨ សន្និសីទអន្តរជាតិទីក្រុងតេហេរ៉ង់ស្តីពីសិទ្ធិមនុស្សបានទទួលស្គាល់

---

ខែ ឧសភា ឆ្នាំ ២០១៥, ទំព័រ ៧។ រស់ ហ៊ឹម, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D118/258**, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤, ទំព័រ ១២។

[71] ព្រាប សុខឿន, *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/24**, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៤, ទំព័រ ១៥-១៦។ វ៉ាន់ សង, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D219/243**, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥, ទំព័រ ១០។ *សូមមើលផងដែរ* Theresa de Langis, Judith Strasser, Thida Kim, Sopheap Taing, "*ដូចខ្មោចប្រែកាឡាខ្លួន៖ ការសិក្សាពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម*", អង្គការចិត្តសង្គមអន្តរវប្បធម៌ (ឆ្នាំ២០១៤), ទំព័រ៨១៖ "ពាក់កណ្តាលនៃបទសម្ភាសន៍ករណីសិក្សាជាមួយស្ត្រីបានរៀបរាប់ថា ពួកគេត្រូវបានប្តីរំលោភ"។

[72] ពៅ ឈុនឡេង, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/1165**, ទំព័រ៣។ ជួន ណារី, *ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D5/1335** ,ទំព័រ ៣, ៤។

[73] *ព្រះរាជអាជ្ញា v. Kupreskic*, IT-95-16-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង), ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០, កថាខណ្ឌ ៥៦៦, ភ្ជាប់ជាឧបសម្ព័ន្ធ ២០។

សិទ្ធិមនុស្សជាមូលដ្ឋានក្នុងការកំណត់ដោយសេរី និងដោយការទទួលខុសត្រូវលើចំនួនកូន និងការពន្យារកំណើត[74]។ ការអនុម័តលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលរួមបញ្ចូលឧក្រិដ្ឋកម្មដោយឡែកនៃការមានផ្ទៃពោះដោយបង្ខំនៅឆ្នាំ ១៩៩៨[75] និងការដាក់បញ្ចូលបទប្បញ្ញត្តិដែលដាក់ទោសព្រហ្មទណ្ឌលើអំពើ ដែលមានចែងក្នុងលក្ខន្តិកៈ SCSL[76] ហើយក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត ("SPSC")[77] បានបញ្ជាក់បន្ថែមទៀតថា ការមានផ្ទៃពោះដោយបង្ខំ គឺជាបទល្មើសដែលមានស្ថានទម្ងន់ស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែលមានចែងក្នុងមាត្រា ៥។

(៤) <u>លក្ខខណ្ឌទូទៅ</u>

48. ដើម្បីបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" អំពើនោះត្រូវបំពេញលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីធានាថា អំពើនេះមានភាពដាច់ដោយឡែកពីឧក្រិដ្ឋកម្មក្នុងប្រទេស ឬឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត ដូចជាត្រូវតែមានការវាយប្រហារដែលមានលក្ខណៈទូទៅ ឬជាប្រព័ន្ធ ដែលសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[78]។

---

[74] ជំពូក XVIII នៃសេចក្ដីប្រកាសទីក្រុងតេហេរ៉ង់, វិធានការចុងក្រោយនៃសន្និសីទអន្តរជាតិស្ដីពីសិទ្ធិមនុស្សទីក្រុងតេហេរ៉ង់, ថ្ងៃទី ២២ ខែ មេសា រហូតដល់ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ១៩៦៨, ឯកសារអង្គការសហប្រជាជាតិ A/CONF. 32/41 (ឆ្នាំ១៩៦៨), ភ្ជាប់ជាឧបសម្ព័ន្ធ ២១។

[75] មាត្រា ៧, កថាខណ្ឌ ១ ឆ), កថាខណ្ឌ ២ ច) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨, 2187 UNTS 90 (អំណឹះតទៅហៅថា "លក្ខន្តិកៈ ICC"), ភ្ជាប់ជាឧបសម្ព័ន្ធ ២២។

[76] មាត្រា ២ ឆ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន អនុលោមតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៣១៥ (ឆ្នាំ២000) ដើម្បីបង្កើតលក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ដែលចុះហត្ថលេខានៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២00២, 2178 UNTS 137 (អំណឹះតទៅហៅថា "លក្ខន្តិកៈ SCSL"), ភ្ជាប់ជាឧបសម្ព័ន្ធ ២៣។

[77] មាត្រា ៥.១ ឆ) បទប្បញ្ញត្តិ ២000/១៥ ស្ដីពីការបង្កើតក្រុមប្រឹក្សាដែលមានយុត្តាធិការពិសេសលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ, UNTAET/REG/2000/15, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២000 (អំណឹះតទៅហៅថា "បទប្បញ្ញត្តិ SPSC"), ភ្ជាប់ជាឧបសម្ព័ន្ធ ២៤។

[78] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង 00២/១៩-0៩-២00៧/អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E313**, *សាលក្រមសំណុំរឿង 00២/0១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១៧៧។ មាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

49. ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ របស់គាត់ ស.ព.អ បានបញ្ជាក់ច្បាស់ពីធាតុផ្សំទូទៅនៃអាពាហ៍ពិពាហ៍ដោយបង្ខំដោយលើកឡើងថា គាត់មានមូលហេតុដែលនាំឱ្យជឿបានថា ឧក្រិដ្ឋកម្មដែលមានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ត្រូវបានកំណត់ថាជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មទូទៅ ឬសហឧក្រិដ្ឋកម្មរួម ដែលបំពេញលក្ខខណ្ឌឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[79]។

## II. ធាតុផ្សំជាក់លាក់នៃការមានផ្ទៃពោះដោយបង្ខំដែលជាផ្នែកមួយនៃអំពើអមនុស្សធម៌ផ្សេងៗទៀត

50. ក្រៅពីការបង្ហាញធាតុផ្សំទូទៅនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ក្រោមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រការចាំបាច់នោះគឺត្រូវមានការកំណត់ថាតើឧក្រិដ្ឋកម្មនៃការមានផ្ទៃពោះដោយបង្ខំ តម្រូវឱ្យមានធាតុផ្សំជាក់លាក់បន្ថែម ឬយ៉ាងណា ដើម្បីញែកឱ្យដាច់ពីបទល្មើសនេះចេញពីសកម្មភាពនានាដែលបានរៀបរាប់ក្នុងមាត្រា ៥។ ទោះបីជាយុត្តិសាស្ត្ររបស់ អ.វ.ត.ក មិនទាន់បានលើកឡើងពីការមានផ្ទៃពោះដោយបង្ខំក្តី ប៉ុន្តែសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២/១ បានផ្តល់ការណែនាំដល់បរិបទនេះ ព្រោះខ្លួនបានកំណត់ ឧក្រិដ្ឋកម្មផ្សេងទៀត មានជាអាទិ៍ ការបាត់ខ្លួនដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការវាយ ប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ដែលត្រូវបានចាត់ចូលក្នុងប្រភេទ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ក្រោមមាត្រា ៥[80]។ ដើម្បីកំណត់ធាតុផ្សំជាក់លាក់នៃឧក្រិដ្ឋកម្មទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើនិយមន័យនានា ដែលបង្កើតឡើងដោយលក្ខន្តិកៈ និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការកូនកាត់ផ្សេងទៀត។

51. កន្លងមកមិនទាន់មានតុលាការអន្តរជាតិ ឬតុលាការកូនកាត់ណាមួយបានជំនុំជម្រះឧក្រិដ្ឋកម្ម មានផ្ទៃពោះដោយបង្ខំឡើយ[81] ប៉ុន្តែនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានចែងក្នុងមាត្រា ៧ (២) lit. (ច) នៃលក្ខន្តិកៈ ICC និងក្នុងមាត្រា ៥.២ ង) នៃបទបញ្ញត្តិ SCSL៖

---

[79] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤, ឯកសារ **D191**, កថាខណ្ឌ ១៣-១៤។

[80] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ជ, ឯកសារ **E313**, *សាលក្រមសំណុំរឿង ០០២/០១*, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៤៨, ៤៥០, ៤៥៧។

[81] Maria Lobato,"ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម" (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ៧-៨។

*"ការមានផ្ទៃពោះដោយបង្ខំ" សំដៅលើការឃុំខ្លួនស្ត្រីខុសច្បាប់ ហើយបង្ខំឲ្យមានផ្ទៃពោះ ក្នុងបំណងបង្កផលប៉ះពាល់ដល់ធាតុផ្សំជាតិពន្ធុរបស់ក្រុមប្រជាជនណាមួយ ឬធ្វើឲ្យមាន ការបំពានធ្ងន់ធ្ងរផ្សេងទៀតលើច្បាប់អន្តរជាតិ។ និយមន័យនេះ មិនត្រូវបកស្រាយតាម របៀបណាមួយ ដែលបង្កផលប៉ះពាល់ដល់ច្បាប់ជាតិពាក់ព័ន្ធនឹងការមានផ្ទៃពោះឡើយ"។*

52. ការតាក់តែងច្បាប់ព្រហ្មទណ្ឌស្តីពីការមានផ្ទៃពោះដោយបង្ខំរបស់តុលាការទាំងពីរនេះ បញ្ជាក់ពី ការយល់ដឹងទូទៅអំពីនិយមន័យរបស់វាក្នុងច្បាប់អន្តរជាតិ។ ធាតុផ្សំជាក់លាក់នៃឧក្រិដ្ឋកម្មដែល មានចែងក្នុងច្បាប់ទាំងនេះសុទ្ធតែអាចអនុវត្តបាននៅ អ.វ.ត.ក។

(១) <u>ការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ</u>

53. ទម្រង់បែបបទជាប្រព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យដែលបង្ខំឲ្យបុរស និងស្ត្រីរៀបអាពាហ៍ ពិពាហ៍ និងបង្ខំឲ្យពួកគេបំពេញកិច្ចរួមភេទ គឺជាទម្រង់មួយនៃការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ។ ដូចមានបង្ហាញខាងលើក្នុងករណីជាច្រើន ការរួមភេទធ្វើឡើងក្រោមបទបញ្ជាជាក់លាក់ និងការ គំរាមកំហែងដាក់ទណ្ឌកម្ម[82]។ លើសពីនេះទៀត អំពើរំលោភសេពសន្ថវៈកើតមានជាទូទៅក្នុងអា ពាហ៍ពិពាហ៍ដោយបង្ខំ[83]។ ក្នុងកាលៈទេសៈនេះ កង្វះការយល់ព្រមរួមភេទលេចឡើងយ៉ាងច្បាស់ ហើយទោះបីជាមិនមានការគំរាមកំហែងលើរូបរាងកាយ និងការគំរាមកំហែងដោយផ្ទាល់ក៏ដោយ ក៏ការបង្កឲ្យមានផ្ទៃពោះត្រូវបានបញ្ជាក់តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ស្ថានភាព នេះបូករួមនឹងកង្វះលទ្ធភាពទទួលបានមធ្យោបាយពន្យារកំណើត បានបំពេញលក្ខខណ្ឌនៃការបង្ក ឲ្យមានផ្ទៃពោះដោយបង្ខំ។

(២) <u>ការឃុំខ្លួនដោយខុសច្បាប់</u>

54. ធាតុផ្សំបន្ថែមទៀតនៃការឃុំខ្លួនដោយខុសច្បាប់មានពាក់ព័ន្ធទៅនឹងការបង្ខំឲ្យស្ត្រីពរពោះរហូត ដល់គ្រប់ខែ និងធ្វើការដកហូតដោយខុសច្បាប់នូវសេរីភាព និងការបដិសេធក្នុងការទទួលបានការ រម្លូតកូន[84]។ បទបញ្ជារបស់ ប.ក.ក បង្ហាញពីគោលនយោបាយដែលពលរដ្ឋស្ទើរតែទាំងអស់ត្រូវ

---

[82] *សូមមើល* ជើងទំព័រ ១៨។

[83] *សូមមើល* ជើងទំព័រ ៧១។

[84] Maria Lobato, "ការមានផ្ទៃពោះដោយបង្ខំក្នុងរបបខ្មែរក្រហម" (ខែ មីនា ឆ្នាំ ២០១៦), ទំព័រ ២៥។

បានបង្ខំឱ្យរស់នៅក្នុងសហករណ៍ និងការដ្ឋានការងារ[85]។ ការណ៍នេះគឺជាកាលៈទេសៈ ដែលស្ត្រីទទួលរងការរិតត្បិតផ្នែករូបរាងកាយ ឬសីលធម៌ ក្រោមការគំរាមកំហែងប្រព្រឹត្តអំពើហិង្សា និងការបង្ខិតបង្ខំដោយផ្ទាល់។ ដោយសារតែអង្គហេតុនេះ និងការបដិសេធលទ្ធភាពទទួលបានការរម្លូតកូននេះហើយទើប អំពើនេះបំពេញលក្ខខណ្ឌខាងលើ។

(៣) <u>ចេតនាឧក្រិដ្ឋ</u>

55. ឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ តម្រូវឱ្យមានចេតនាជាក់លាក់ក្នុងការបង្កផលប៉ះពាល់ដល់ ធាតុផ្សំជាតិពន្ធុរបស់ប្រជាជនក្រុមណាមួយ ឬបំពានធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ។ ប្រភពមួយចំនួនដែលត្រូវបានដកស្រង់ខាងលើបង្ហាញថា គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺធ្វើឡើងដើម្បីបង្កើនកម្លាំងពលកម្មសម្រាប់ពេលអនាគត[86]។ ភ័ស្តុតាងនៃលក្ខណៈនេះ អាចបង្ហាញពីចេតនាក្នុងបង្កើតឱ្យមានការងារដោយបង្ខំ កាតព្វកិច្ចដោយបង្ខំ ការរិតត្បិតការដើរហើរ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរលើកុមារដែលប្រសូតចេញពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

56. យ៉ាងនេះក្តី ការស៊ើបអង្កេតដែលកំពុងធ្វើឡើង មិនបានពិនិត្យមើលលើទិដ្ឋភាពនេះឡើយរហូតមកដល់ពេលនេះ។ ដូច្នេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះដូចខាងក្រោម យល់ឃើញថា ការស៊ើបអង្កេតលើចំណុចនេះមានភាពចាំបាច់ ដើម្បីកំណត់ថាតើ អោ អាន [redacted] មានចេតនាបំពារបំពានធ្ងន់ធ្ងរលើច្បាប់អន្តរជាតិតាមរយៈការឃុំខ្លួនស្ត្រីដោយបង្ខំឱ្យមានផ្ទៃពោះមានទំហំប៉ុណ្ណា។

## III. ភាពខុសគ្នារវាងការមានផ្ទៃពោះដោយបង្ខំ បទល្មើសជាក់លាក់ផ្សេងទៀត និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

57. ដើម្បីបញ្ជាក់ពី "អំពើអមនុស្សធម៌ផ្សេងៗទៀត" ឧក្រិដ្ឋកម្មការមានផ្ទៃពោះដោយបង្ខំត្រូវមានទិដ្ឋភាព និងធាតុផ្សំជាក់លាក់ដែលមិនមែនជាផ្នែកណាមួយនៃឧក្រិដ្ឋកម្មដែលមានការទទួលស្គាល់

---

[85] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ E313, សាលក្រមសំណុំរឿង ០០២/០១, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១០២, ១១៣។

[86] *សូមមើល* កថាខណ្ឌ ១៧ ខាងលើ។

រួចហើយថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[87]។ ការមានផ្ទៃពោះដោយបង្ខំ មានទិដ្ឋភាពជាច្រើនដែលមានលក្ខណៈដូចគ្នាទៅនឹងចំណុចនានានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប៉ុន្តែទោះជាយ៉ាងណា នៅតែរួមបញ្ចូលធាតុផ្សំដោយឡែកមួយចំនួន ដែលមិនមានការបញ្ជាក់គ្រប់គ្រាន់ដោយឧក្រិដ្ឋកម្មផ្សេងៗ ដែលបានបង្ហាញរួចហើយ។

58. ឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ និងការដាក់ពន្ធនាគារ រួមបញ្ចូលទាំងទិដ្ឋភាពនៃការឃុំខ្លួនដែលជាចំណុចសំខាន់ក្នុងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ។ ទោះជាយ៉ាងនេះក្តី ឧក្រិដ្ឋកម្មនេះមិនបានបញ្ជាក់ការមានផ្ទៃពោះដោយបង្ខំនោះទេ។ ឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្ម គ្របដណ្តប់លើអំពើដែលបណ្តាលឱ្យមានការតាំងគភ៌ដោយបង្ខំ ក៏ប៉ុន្តែមិនតម្រូវឱ្យមានការមានផ្ទៃពោះដោយសារឧក្រិដ្ឋកម្មនោះឡើយ។

59. ម្យ៉ាងទៀតតាមលក្ខណៈរបស់វា ការមានផ្ទៃពោះដោយបង្ខំ គឺជាឧក្រិដ្ឋកម្មផ្អែកយេនឌ័រដែលជះឥទ្ធិពលតែលើស្ត្រីប៉ុណ្ណោះ។ ក្នុងន័យនេះ ឧក្រិដ្ឋកម្មនេះមិនត្រឹមតែមានលក្ខណៈខុសគ្នាពីបទល្មើសជាក់លាក់ផ្សេងទៀតប៉ុណ្ណោះទេ ថែមទាំងខុសពីឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ ដោយសារទម្រង់នៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត” ដែលក្នុងបរិបទបច្ចុប្បន្ន កំណត់គោលដៅទៅលើទាំងស្ត្រី ទាំងបុរស។ ការស្តាប់ចម្លើយរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (បុរស) ក្នុងសំណុំរឿង ០០៤ បង្ហាញថា បុរសប្រឈមនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំច្រើនដូចស្ត្រីដែរ[88] ប៉ុន្តែស្ត្រីដែលមានផ្ទៃពោះដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវស៊ូទ្រាំនឹងទម្រង់រងគ្រោះដាច់ដោយឡែកមួយដោយសារតែការមាន

---

[87] ទឡ្ហីករណ៍ស្រដៀងគ្នាមួយត្រូវបានធ្វើឡើងក្នុងសេចក្តីសន្និដ្ឋានមួយរបស់ ស.ព.អ ថ្មីៗនេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ៖ ការិយាល័យសហព្រះរាជអាជ្ញាអន្តរជាតិ, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២១/០០៤), ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការឆ្លើយតបរបស់គាត់ទៅនឹងសារអេឡិចត្រូនិចរបស់អង្គបុរេជំនុំជម្រះ, ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D257/1/3**, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥, កថាខណ្ឌ ២៥, ភ្ជាប់ជាឧបសម្ព័ន្ធ ២៥។

[88] សិន បាន, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, *កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី*, ឯកសារ **D219/306,** ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៥, ទំព័រ ៦-៧។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី លី លន់, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ **D118/248**, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៤, ទំព័រ ២១-២២។

ផ្ទៃពោះ និងការសម្រាលកូនស្ថិតក្នុងស្ថានភាពលំបាកវេទនាដែលបានលើកឡើងខាងលើ។ ជាងនេះទៀត កម្រិតនៃការគ្រប់គ្រងរបស់រដ្ឋលើរាងកាយរបស់ស្ត្រីតាមរយៈការមានផ្ទៃពោះដោយបង្ខំ បង្កើតបានជាការបញ្ជាក់ក្នុងទម្រង់ច្បាស់លាស់របស់ស្ត្រីរងគ្រោះថាមានភាពដាច់ដោយឡែក និងមិនផ្គុះបញ្ចាំងក្នុងឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ ដូច្នេះ ការមានផ្ទៃពោះដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ សាកសមនឹងត្រូវផ្ដន្ទាទោសដោយឡែកដើម្បីទទួលស្គាល់ព្យសនកម្មដាច់ដោយឡែកដែលបង្កឡើងដោយឧក្រិដ្ឋកម្មនីមួយៗ។

## គ. សំណើស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម

60. យោងតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចត្រឹមតែស៊ើបអង្កេតលើអង្គហេតុនានា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមប៉ុណ្ណោះ[89]។ ដូច្នេះ ការចោទប្រកាន់លើអង្គហេតុដែលលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ មានមូលដ្ឋានសម្រាប់ឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ។

61. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី បញ្ជាក់ថា ក្រោមការដឹកនាំរបស់ ប.ក.ក ប្រជាជនកម្ពុជាគឺជាកម្មវត្ថុនៃរបបគៀបសង្កត់មួយ ដែលព្យាយាមគ្រប់គ្រងទាំងស្រុងលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅរបស់ប្រជាជន[90]។ យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ កើតមាននៅក្នុងបណ្ដាស្រុកនានា ដែលស្ថិតក្រោមការត្រួតត្រា ឬអំណាចរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៤ ហើយ "ជនរងគ្រោះក្រោមការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ត្រូវបានតាមដានដោយឈ្លបយកការ ឬកងឈ្លប ដើម្បីធានាឲ្យប្រាកដថា ពួកគេពិតជាបានរួមដំណេកជាមួយគ្នា ដែលនេះគឺជាកាលៈទេសៈដែលមានលក្ខណៈបង្ខិតបង្ខំជាប់មកជាមួយស្រេចដែលពួកកម្មាភិបាល ប.ក.ក បានបង្កើតឡើង និងបន្តអនុវត្ត"[91]។ ដូច្នេះ ការចោទប្រកាន់ផ្នែកអង្គហេតុទាំងនេះ បង្ហាញពីធាតុផ្សំជាក់លាក់នៃការមានផ្ទៃ

[89] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក, វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។

[90] *សូមមើល* ការបរិយាយក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី, ឯកសារ **D1**, កថាខណ្ឌ ៦-៨។

[91] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ឆ្នាំ ២០១៤, ឯកសារ **D191**, ទំព័រ ៣, កថាខណ្ឌ ១-២។

ពោះដោយបង្ខំ ដូចបានលើកឡើងខាងលើដែលការមានផ្ទៃពោះដោយបង្ខំនេះ តម្រូវឱ្យស្ត្រីមានផ្ទៃពោះទាំងបង្ខំ។

62. យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី សេរីភាពដើរហើររបស់ប្រជាជនត្រូវបានរិតត្បិត និងគ្រប់គ្រងយ៉ាងតឹងរ៉ឹង[92]។ ជនស៊ីវិលត្រូវបានចាត់តាំងឱ្យធ្វើការតាមការដ្ឋាន ហើយការចាកចេញពីការដ្ឋានការងារដែលបានចាត់តាំង ត្រូវមានការអនុញ្ញាតពីកម្មាភិបាល ប.ក.ក[93]។ ដោយហេតុថាគោលការណ៍នេះក៏អនុវត្តចំពោះស្ត្រី ដែលមានផ្ទៃពោះដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែរនោះ ការចោទប្រកាន់ទាំងនេះគឺជាមូលដ្ឋាននៃធាតុផ្សំនៃការឃុំខ្លួនដែលចាំបាច់សម្រាប់ធាតុផ្សំនៃឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

63. ដូច្នេះ សារណានេះ មិនមានបំណងនាំមកនូវការស៊ើបអង្កេតលើកបណ្តុំអង្គហេតុថ្មីទាំងមូលឡើយ ប៉ុន្តែគ្រាន់តែស្នើឱ្យ ក.ស.ច.ស ស៊ើបអង្កេតតាមដានបន្តដោយសមហេតុផលលើអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពោលគឺបញ្ហានៃការជំរុញឱ្យមានការអនុវត្តគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានបង្កឱ្យមានការមានផ្ទៃពោះដោយឥតគ្រោងទុក។

## ឃ. សេចក្តីសន្និដ្ឋាន

64. ការមានផ្ទៃពោះដោយបង្ខំ គួរត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយឡែកមួយស្ថិតក្រោមបទប្បញ្ញត្តិនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ ការស៊ើបអង្កេត និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ មិនបានរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពឡើយ។ ឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំបំពេញលក្ខខណ្ឌតម្រូវទូទៅដែលបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ ធាតុផ្សំជាក់លាក់នៃឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ តម្រូវឱ្យមានការឃុំខ្លួនដោយបង្ខំលើស្ត្រីដែលបង្កឱ្យមានផ្ទៃពោះ ដោយមានបំណងធ្វើឱ្យប៉ះពាល់លើ ធាតុផ្សំជាតិពន្ធុរបស់ប្រជាជន ឬបង្កការរំលោភបំពានធ្ងន់ធ្ងរផ្សេងទៀតលើច្បាប់អន្តរជាតិ។ ការស៊ើបអង្កេតបច្ចុប្បន្នមិនបានផ្តោតលើចេតនាជាក់លាក់ចាំបាច់លើឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំនោះទេ។ ទិដ្ឋភាពនេះ

---

[92] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ឯកសារ **D1**, កថាខណ្ឌ ៧, ៩០ ច, ៩៨ ជ។

[93] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ឯកសារ **D427**, *ដីកាដំណោះស្រាយ*, កថាខណ្ឌ ១៦៨, ៣១០។

ត្រូវបានគ្របដណ្តប់ដោយអង្គហេតុនានា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

## VIII. សំណើ

65. ដោយសារតែហេតុផលទាំងនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះដូចខាងក្រោម សូមគោរពស្នើសុំសហចៅក្រមស៊ើបអង្កេតមេត្តា៖

I. ទទួលយកសំណើសុំបន្ថែមចំនួនទំព័ររហូតដល់ ២៥ ទំព័រ និងដាក់ឯកសារជាភាសាអង់គ្លេសជាមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។

II. បំពេញកិច្ចស៊ើបសួរបន្ថែមដើម្បីបង្ហាញពីចេតនារបស់ជនសង្ស័យ អោ អាន [redacted] ក្នុងសំណុំរឿង ០០៤ ដែលបានរំលោភបំពានធ្ងន់ធ្ងរលើច្បាប់អន្តរជាតិតាមរយៈការឃុំខ្លួនស្ត្រីម្នាក់ ឬច្រើននាក់ដោយបង្ខំរហូតបណ្តាលឱ្យមានផ្ទៃពោះ និង

III. ក្នុងករណីដែលមានភស្តុតាងសំអាងគ្រប់គ្រាន់ ចោទប្រកាន់ការមានផ្ទៃពោះដោយបង្ខំថាជាឧក្រិដ្ឋកម្មដោយឡែកមួយប្រឆាំងមនុស្សជាតិ អនុលោមតាមបទប្បញ្ញត្តិនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត"។

សូមដាក់សំណើនេះដោយក្តីគោរពពី៖

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា និងត្រា |
|---|---|---|---|
| ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៦ | អ្នកស្រី ស៊ិន ស៊ុវ៉ន<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | លោក ហុង គីមសួន<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | លោក ឡោ ជុនធី<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | Linda BEHNKE<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | Beini YE<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ទីក្រុងឡុងដ៍ | |